**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:២៤២៥....សហវ.ហក

រាជធានីភ្នំពេញ ថ្ងៃទី២៩ខែ ធ្នូ ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពី

## ការប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ននៅរដ្ឋបាលកណ្តាលក្នុងការពិនិត្យសំរេចចុះទិដ្ឋាការលើលិខិតធានាចំណាយនិងលើអាណត្តិបើកប្រាក់

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអំពីប្រពន្ធ័ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិនានានៃវិសោធនកម្មច្បាប់នេះ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ-បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ-បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៥៦សហវ-ប្រក ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋានហិរញ្ញកិច្ច
- ផ្អែកតាមសកម្មភាព ៦.១.១ ស្តីពីការពិនិត្យឡើងវិញលើបទបញ្ញាប្រកាសដែលកំពុងអនុវត្តលើការផ្តល់សិទ្ធិធានាចំណាយ និងអាណត្តិទូទាត់ ក្នុងក្របខណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- តាមស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦

## សម្រេច

**ប្រការ១ :** ប្រគល់សិទ្ធិសម្រេចទទួលខុសត្រូវចុះទិដ្ឋាការលើលិខិតធានាចំណាយ និងលើអាណត្តិបើកប្រាក់ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួង ស្ថាប័នរដ្ឋបាលកណ្តាល សំរាប់មុខចំណាយមួយចំនួនដូចខាងក្រោម ÷

- ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់មន្ត្រីរាជការ ដែលមានទិដ្ឋាការយល់ព្រមពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ប្រាក់កម្រៃរបស់បុគ្គលិកជាប់កិច្ចសន្យាឬបុគ្គលិកអណ្តែត ដែលមានទិដ្ឋាការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- មន្ត្រីមានជំងឺ និងឧបត្ថម្ភមន្ត្រីសំរាលកូន
- មរណៈភាព
- ឧបត្ថម្ភម្តងគត់ជូននិវត្តជន
- ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ
- ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ
- អាហារូបករណ៍សំរាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស។

**ប្រការ២ :** មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ន មានសិទ្ធិសំរេចទទួលខុសត្រូវចុះទិដ្ឋាការចំពោះមុខចំណាយមួយចំនួនដូចមានចែងក្នុងប្រការ ១ ខាងលើ ទៅតាមចំនួនទឹកប្រាក់ដូចខាងក្រោម ÷

- ***មិនមានកំណត់ចំនួនទឹកប្រាក់សំរាប់មុខចំណាយ ÷***

+ ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់មន្ត្រីរាជការ ដែលមានទិដ្ឋាការយល់ព្រមពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

+ ប្រាក់កម្រៃរបស់បុគ្គលិកជាប់កិច្ចសន្យា ឬបុគ្គលិកអណ្តែត ដែលមានទិដ្ឋាការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

- ***ក្រោមចំនួនទឹកប្រាក់ ៥០ លានរៀល សំរាប់មុខចំណាយដែលមានរបបកំណត់ច្បាស់លាស់ដូចខាងក្រោម ÷***

+ ឧបត្ថម្ភមន្ត្រីមានជំងឺ និងឧបត្ថម្ភមន្ត្រីសំរាលកូន

+ ឧបត្ថម្ភមរណៈភាព

+ ឧបត្ថម្ភម្តងគត់ជូននិវត្តជន

+ ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ

+ ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ

+ អាហារូបករណ៍សំរាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស ។

**ប្រការ៣ :** ភារកិច្ចទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ននៅរដ្ឋបាលកណ្តាលមានដូចខាងក្រោម ÷

- ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ ត្រឹមត្រូវ សមស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ-បក ចុះថ្ងៃ ទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល និងសារាចរណែនាំលេខ ០០៥ សហវ-ហ.សរណន ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ

- មិនអនុញ្ញាតឱ្យធ្វើការបំបែកគំរោងចំណាយ ទៅជាគំរោងចំណាយតូចៗ ដើម្បីតំរូវទៅតាមកំរិតទឹកប្រាក់ដែលបានប្រគល់សិទ្ធិសំរេច ។

- ត្រួតពិនិត្យជាមុនអំពីភាពត្រឹមត្រូវនៃការស្នើសុំចំណាយ ជាពិសេសត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃការធានាចំណាយជាមួយនឹងឥណទានទំនេរ និងផ្ទៀងផ្ទាត់រវាងការបញ្ជាអាណត្តិទូទាត់ជាមួយនឹងកិច្ចសន្យាលទ្ធកម្មសាធារណៈ ។

- ត្រួតពិនិត្យពីភាពត្រឹមត្រូវនៃលិខិតយុត្តិការ (សក្ខីប័ត្រ) ដែលទាក់ទងនឹងសំណុំរឿងស្នើសុំចំណាយមុននឹងធ្វើការទូទាត់ ។

- ផ្តល់ការណែនាំអំពីនីតិវិធីចំណាយចំពោះផ្នែកនានារបស់អាណាប័ក ក្នុងគោលបំណងបង្ការទុកជាមុននូវភាពមិនប្រក្រតី ដើម្បីចៀសវាងចំណាយគ្មានតម្លាភាព ឬចំណាយលើសពីឥណទានអនុម័តដែលធ្វើឱ្យរដ្ឋជំពាក់បំណុលគេ ។

- ត្រូវធ្វើការសិក្សាស្វែងយល់អំពីគោលនយោបាយជាអាទិភាពរបស់ក្រសួងសាមី ដើម្បីបង្កើនលទ្ធភាពឱ្យអាណាប័កចំណាយតាមឥណទានថវិកាដែលបានអនុម័ត ។ ប៉ុន្តែក៏ត្រូវអនុវត្តយ៉ាងហ្មត់ចត់នូវវិន័យថវិកា និងតាមលិខិតបទដ្ឋានដែលមានចែងជាធរមាន ។
- កាន់កាប់បញ្ជីគណនេយ្យធានាចំណាយ និងអាណត្តិកិច្ចឱ្យបានទៀងទាត់ និងត្រឹមត្រូវ ដោយធ្វើការផ្ទៀងផ្ទាត់តួលេខអោយស៊ីគ្នាជាប្រចាំជាមួយនឹងផ្នែកគណនេយ្យរដ្ឋបាលរបស់អាណាប័ក និងជាមួយនឹងផ្នែកចំណាយរបស់រតនាគារជាតិ ។
- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍អំពីការអនុវត្តនីតិសិទ្ធិសំរេចទទួលខុសត្រូវរបស់ខ្លួន ទាំងការធានាចំណាយ ទាំងការបញ្ចេញអាណត្តិជូននាយកដ្ឋានហិរញ្ញកិច្ចឱ្យបានទៀងទាត់ ដើម្បីធ្វើការបូកសរុប ។

**ប្រការ៤ :** មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ន ត្រូវមានស្មារតីសាមគ្គីភាព និងរក្សានូវសីលធម៌វិជ្ជាជីវៈឱ្យបានត្រឹមត្រូវ ។

**ប្រការ៥ :** រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ន ព្រមទាំងប្រធាននាយកដ្ឋាន អង្គភាពពាក់ពន្ធ័ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ តទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួងស្ថាប័នដែលមានមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៅអមផ្ទាល់
  "ដើម្បីសហការអនុវត្ត"
- គ្រប់នាយកដ្ឋាន អង្គភាព ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុពាក់ពន្ធ័ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- ឯកសារ និងកាលប្បវត្តិ